# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...១២...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ដែលស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យកែសំរួលលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញសេចក្តីសំរេចលេខ ៣២ សសរ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការដោះស្រាយបញ្ហាក្ញូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា
- យោងតាមតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១ :** ត្រូវបានបង្កើតគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ដែលជាគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលកើតមានឡើង ចំពោះអ្នកវិនិយោគ សំដៅកែលំអបន្ថែមបរិយាកាសសម្រាប់ការវិនិយោគ និងជំរុញឱ្យការអនុវត្តគម្រោងវិនិយោគប្រព្រឹត្តទៅប្រកបដោយ ជោគជ័យ ។

គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ បំពេញភារកិច្ចនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស ដោយមិនដោះស្រាយនូវបញ្ហាដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការដោះស្រាយបញ្ហា នៃតំបន់សេដ្ឋកិច្ចពិសេស ដែលកំណត់ដោយអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៥ នោះឡើយ ។

**មាត្រា២ :** គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| ១. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| ២. លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ | អនុប្រធានទី១ |
| ៣. ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធានទី២ |
| ៤. ឯកឧត្តម អ៊ឹម ឈុនលឹម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥. ឯកឧត្តម ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៦. ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧. ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩. ឯកឧត្តម សុខ ចិន្តា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិកប្រចាំការ |
| ១០. ឯកឧត្តម ចន្ទ័ តានី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១. ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១២. ឯកឧត្តម ម៉ឹង សំផន រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១៣. ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤. ឯកឧត្តម សូ ម៉ាភ៉ា រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៥. ឯកឧត្តម សយ ស៊ីផុន រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៦. លោកជំទាវ ចន្ទ័ សុធាវី រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |

១៧. ឯកឧត្តម នូ សុវត្ថិ រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១៨. ឯកឧត្តម នាយឧត្តមសេនីយ៍ គន់ គីម អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ សមាជិក
១៩. ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ សមាជិក
២០. ឯកឧត្តម ឧត្តមសេនីយ៍ សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
២១. ឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ
និងជាអគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សមាជិក
២២. ឯកឧត្តម សំ សុផល អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
២៣. ឯកឧត្តម គី តិច មេធាវីរាជរដ្ឋាភិបាល សមាជិក
២៤. អភិបាលរាជធានីភ្នំពេញ-ខេត្ត សមាជិក
២៥. ឯកឧត្តម ឯម សុភ័ណ្ឌ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
២៦. ឯកឧត្តម សួន សិទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា លេខាធិការ

**មាត្រា៣** : គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានតួនាទី និងភារកិច្ចដូចតទៅ ÷

-ជាយន្តការទទួលពាក្យបណ្តឹងតវ៉ា និងដោះស្រាយបញ្ហាដែលស្នើសុំដោយអ្នកវិនិយោគ

-ដោះស្រាយនូវរាល់បញ្ហាជាបន្ទាន់ទាំងឡាយរបស់អ្នកវិនិយោគ ដែលមានឥទ្ធិពលប៉ះពាល់ដល់បរិស្ថានវិនិយោគ និងសេដ្ឋកិច្ចជាតិ ដែលហួសពីសមត្ថកិច្ចរបស់អនុគណៈកម្មាធិការវិនិយោគរាជធានីភ្នំពេញ-ខេត្ត ឬគណៈកម្មាធិការវិនិយោគកម្ពុជា ទាំងលើទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពច្បាប់ ។

-សហការជាប្រចាំជាមួយ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាក្ងដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា និងស្ថាប័នមានសមត្ថកិច្ច ដែលពាក់ព័ន្ធនឹងបញ្ហាវិនិយោគ ។

-ធ្វើរបាយការណ៍ អំពីសកម្មភាពការងាររបស់គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា៤** : គណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ មានទីតាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិប្រើប្រាស់ត្រា និងប្រើប្រាស់ថវិកាចំណាយ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ លេខាធិការដ្ឋាន នៃគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ មានលេខាធិការមួយរូប ជាអ្នកដឹកនាំ អមដោយជំនួយការមួយចំនួន តាមការចាំបាច់ ។

**មាត្រា៥** : សមាជិកទាំងអស់នៃគណៈកម្មាធិការដោះស្រាយបញ្ហារបស់អ្នកវិនិយោគ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន អនុប្រធាន តាមការប្រគល់សិទ្ធិ ។ សម្រាប់ករណីពិសេស គណៈកម្មាធិការមានសិទ្ធិអញ្ជើញឱ្យចូលរួមប្រជុំផងដែរ នូវរាល់តំណាងក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ ។

**មាត្រា៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី

ក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ